**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលព្រៃឈើ

នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ

ភ្នំពេញ ថ្ងៃទី ខែមីនា ឆ្នាំ២០១៤

ក្រុមការងារ វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

**តាមរយៈ:** ប្រធាននាយកដ្ឋានព្រៃឈើ និង សហគមន៍ព្រៃឈើ

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំបច្ចេកទេសវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់(MRV) លើកទី៥។

**ជូនភ្ជាប់:** -រូបថតសកម្មភាពនៃកិច្ចប្រជុំ..........ចំនួន១ច្បាប់

-បញ្ជីវត្តមាន..........ចំនួន១ច្បាប់

-ឯកសារបទបង្ហាញ..........ចំនួន២ច្បាប់

នំយដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ យើងខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេស វាស់វែង រាយការណ៍ និង ផ្ទៀងផ្ទាត់ (MRV) បានរៀបចំកិច្ចប្រជុំលើកទី៥ នៅសណ្ឋាគារ អ៊ីមផារៀល ហ្គាដិនវីឡា រាជធានីភ្នំពេញ ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

## I-**សមាសភាពចូលរួម**

កិច្ចប្រជុំនេះមានសមាជិកចូលរួមចំនួន ០៦ នាក់ (ដូចបញ្ជីវត្តមាននៃឯកសារជូនភ្ជាប់) មកពី៖

-រដ្ឋាភិបាល: រដ្ឋបាលព្រៃឈើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រុមប្រឹក្សាយោបល់: អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន(JICA) សមាគមន៍ជនជាតិដើមភាគតិចកម្ពុជា (CIYA) ។

## II-**គោលបំណងនៃអង្គប្រជុំ**

គោលបំណងនៃអង្គប្រជុំធ្វើការពិភាក្សាស្តីអំពី៖

-និយមន័យព្រៃឈើជាតិ (National Forest Definition)

-និតិវិធីនៃការរៀបចំបង្កើតផែនទីគោល (Base Map)

## III-**ដំណើរការកិច្ចប្រជុំ**

ក្រុមប្រឹក្សាយោបល់ បានធ្វើបទបង្ហាញចែករំលែកបទពិសោធន៍ជូនអង្គប្រជុំដូចខាងក្រោម៖

-លោក Mathieu VanRijn ធ្វើបទបង្ហាញស្តីអំពីនិយមន័យព្រៃឈើរបស់ប្រទេស កម្ពុជាកន្លងមក។ ក្នុងបទបង្ហាញបានចែករំលែកពត៌មានសំខាន់ៗបីគឺ៖

**១.និយមន័យព្រៃឈើ(អន្តរជាតិ) មាន៖**

-កិច្ចប្រជុំ COP19 នៃក្របខ័ណ្ឌសហប្រជាជាតិស្តីពីបម្រែបម្រួលអាកាសធាតុ (UNFCCC) សម្រេចថាៈ និយមន័យព្រៃឈើសម្រេចតាមប្រព័ន្ធត្រួតពិនិត្យព្រៃឈើថ្នាក់ជាតិ

-អង្គការស្បៀងអាហារពិភពលោក (FAO/FRA) និយមន័យព្រៃឈើពិភពលោកៈ កម្ពស់អប្បបរមា ៥ម៉ែត្រ គម្របកន្សោមស្លឹកតិចបំផុត ១០% ទំហំផ្ទៃដីអប្បបរមា 0.៥ហិកតា ។

**២.និយមន័យព្រៃឈើ(ជាតិ) មាន៖**

-ច្បាប់ព្រៃឈើ៖ ព្រៃឈើគឺជាឯកតានៃប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ ឬសប្បនិមិត្តក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួតដែលគ្របដណ្តប់ដោយរុក្ខជាតិចំរុះ ទោះបីដុះដោយធម្មជាតិក្តី ឬដោយដាំក្តី រួមទាំងធនធានសត្វព្រៃ និងធនធានធម្មជាតិដ៏ទៃដែលស្ថិតនៅក្នុងនោះ ដែលមានគោលបំណងប្រើប្រាស់សំខាន់គឺផលអនុផលព្រៃឈើ ឬសេវាកម្មផ្តលដោយព្រៃ។

-កម្មវិធីព្រៃឈើជាតិ៖ព្រៃឈើគឺជាឯកតានៃប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ ឬសប្បនិមិត្តក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិដុះដោយធម្មជាតិ ឬដាំ មានកម្ពស់ចាប់ពី ៥ម៉ែត្រឡើងលើ ផ្ទៃដីលើសពី 0.៥ហិកតា និងមានកម្រិតគ្របដណ្តប់របស់កន្សោមស្លឹកលើសពី១០ ភាគរយ។ ចម្ការឈើដាំ ដូចជាកៅស៊ូ ដូងប្រេង អាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ និងប្រភេទរុក្ខជាតិផ្តល់ឈើដ៏ទៃទៀត ដែលមានលក្ខណៈដូចរៀបរាប់ខាងលើក៏ត្រូវបានចាត់ចូលជាព្រៃដែរ។

**៣.ចំណុចគួរពិចារណាលើនិយមន័យព្រៃឈើសម្រាប់អនុវត្តREDD+**

ក្រុមការងារបច្ចេកទេស MRV/REL បានលើកជាគំនិត ៣ចំណុចដាក់ជូនថ្នាក់ដឹកនាំធ្វើសេចក្តីសម្រេចចិត្ត ដូចខាងក្រោម៖

-តាមអ្នកសិក្សាស្រាវជ្រាវមួយចំនួនដូចជាលោក Malyvanh និងលោក Feldkotter បានជំទាស់នឹងការចែងរបស់អង្គការស្បៀងអាហារពិភពលោក (FAO) ទៅលើការកំណត់កម្រិតកន្សោមស្លឹកលើសពី១០%។ ដែលកម្រិតកន្សោមស្លឹកនេះ គេអាចប្រើប្រាស់បានក្នុងតំបន់ប្រភេទព្រៃមានគម្របមិនសូវក្រាស់ (open African Woodlands) តែមិនអាចប្រើបានជាមួយប្រភេទព្រៃក្នុងតំបន់អាស៊ីអាគ្នេយ៍ (Forests in South East Asia)បានទេ។

-កាលពីមុនធ្លាប់ផលិតផែនទីគម្របព្រៃឈើ/ផែនទីគម្របដី ដោយអនុវត្តនិយមន័យព្រៃឈើ កម្រិតកន្សោមស្លឹកលើសពី២0% (ក្រសួងបរិស្ថាន ឆ្នាំ២០០៧)

-និយមន័យព្រៃឈើក្នុងកម្មវិធីព្រៃឈើជាតិ និងCDM៖ ដើមឈើមានកម្ពស់ចាប់ពី ៥ម៉ែត្រឡើងលើ ផ្ទៃដីលើសពី 0.៥ហិកតា និងមានកម្រិតគ្របដណ្តប់របស់កន្សោមស្លឹកលើសពី១០ ភាគរយ តែCDMគិតបញ្ចូលសួននៅទីប្រជុំជន ចំការឈើ និងដំណាំកសិកម្មផ្សេងទៀត។

-លោក Ono Shigeru ធ្វើបទបង្ហាញសង្ខេបស្តីអំពីនិតិវិធីនៃការរៀបចំបង្កើតផែនទីគោល (Base Map) ជាពិសេសពាក់ព័ន្ធលក្ខខ័ណ្ឌនៃការកំណត់និយមន័យព្រៃឈើប្រើប្រាស់សម្រាប់អនុវត្តក្នុងកម្មវិធីរ៉េដ។ នៅក្នុងនោះផងដែរ អង្គប្រជុំបានពិភាក្សាគ្នាយ៉ាងលម្អិតទៅលើការកំណត់រយៈពេលនៃការបង្កើតផែនទីកម្រិតបំភាយយោង។

IV-**លទ្ធផលនៃកិច្ចប្រជុំ**

**១.និយមន័យព្រៃឈើ**

ដោយសារកម្មវិធី REDD+ ជាកម្មវិធីជាតិ អង្គប្រជុំសម្រេចអោយស្ថាប័នដទៃពិនិត្យលើនិយមន័យរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងការស្ថាបនានិយមន័យថ្មីប្រើក្នុងកម្មវិធី REDD+កម្ពុជា

**២.ផែនទីគោល**

ប្រើប្រាស់ទិន្នន័យផែនទីដែលមានស្រាប់ តែធ្វើការច្របាច់បញ្ចូលចំណាត់ថ្នាក់ (Harmonize Legend)រវាង ស្ថាប័នផ្សេងៗ ចំពោះការកំណត់ឆ្នាំសម្រាប់ការបង្កើតផែនទីគោល គួរកំណត់យកឆ្នាំ ១៩៩៨ ឆ្នាំ២០០២ ឆ្នាំ ២០០៥/២០០៦ ឆ្នាំ២០១០ និងឆ្នាំ ២០១៣/២០១៤។

V-**គោរពជូនមក**

-ចំពោះនិយមន័យព្រៃឈើសម្រាប់ REDD+ រង់ចាំការឆ្លើយតបពីសមាជិក REL/MRV ពីស្ថាប័នពាក់ព័ន្ធ សិនរួចនឹងដាក់ប្រជុំក្រុមបច្ចេកទេសលើកក្រោយទៀត

-ចំពោះការផលិតផែនទីគោល គួរឯកភាពកំណត់យកឆ្នាំ ១៩៩៨ ឆ្នាំ២០០២ ឆ្នាំ ២០០៥/២០០៦ ឆ្នាំ ២០១០ និងឆ្នាំ ២០១៣/២០១៤ ដោយឡែកការធ្វើចំណាត់ថ្នាក់បញ្ចូលគ្នា ជាបច្ចេកទេសយើងនឹងសហការជាមួយ អង្គការស្បៀងអាហារពិភពលោក (FAO) រៀបចំវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសធ្វើចំណាត់ថ្នាក់នៅខែមេសាខាង មុខ។

VI-**ទិសដៅអនុវត្តបន្ត**

ក្រុមការងារនឹងរៀបចំកិច្ចប្រជុំលើកទី៦ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ក្នុងគោលបំណងធ្វើការពិភាក្សាបន្ត លើសេចក្តីព្រាងផែនការសកម្មភាព REL/MRV។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាពិនិត្យសម្រេចដោយអនុគ្រោះ តាមការគួរ ។

លេខ…………………..នពស

បានឃើញ និង បញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល

ទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

"សូមមេត្តាជ្រាបជាសេចក្តីរាយការណ៍ ដោយអនុគ្រោះ "

ភ្នំពេញ ថ្ងៃទី ខែមីនា ឆ្នាំ២០១៤

**ប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ**

# រូបថតសកម្មភាពនៃកិច្ចប្រជុំ MRV លើកទី៥



